# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទ
# ខេត្តរតនគិរី

## សេចក្តីផ្តើម

ខេត្តរតនគិរី ស្ថិតនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយពីរាជធានីភ្នំពេញ ៥៥៥គ.ម ធ្វើដំណើរតាមផ្លូវជាតិ លេខ៦A ផ្លូវជាតិលេខ៧ និងផ្លូវជាតិលេខ៧៨ ។ ភូមិសាស្ត្រជាតំបន់ខ្ពង់រាប សំបូរភ្នំ និងជ្រោះ ហើយមានទន្លេ ២ ឆ្លងកាត់ (ទន្លេសេសាន និងទន្លេស្រែពក)។ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកន្ទួម និងខេត្តយ៉ាឡាយប្រទេសវៀតណាម ខាងលិចជាប់ខេត្តស្ទឹងត្រែង ខាងជើងជាប់នឹងខេត្តអត្តពឺប្រទេសឡាវ និងខាងត្បូងជាប់នឹងខេត្តមណ្ឌលគិរី ។

- ផ្ទៃដីសរុប (គ.ម ការ៉េ) ៖ **១០ ៧៨២**
- ចំនួនស្រុក/ក្រុង ៖ **៨ ស្រុក ១ក្រុង**
- ចំនួនឃុំ/សង្កាត់៖ **៤៦ ឃុំ ៤ សង្កាត់**
- ចំនួនភូមិ ៖ **២៤៣ ភូមិ**
- ចំណូលមនុស្សម្នាក់ៗប្រចាំឆ្នាំរបស់ខេត្ត(ដុល្លារ) (ទិន្នន័យមន្ទីរផែនការ ២០១៩)៖ **១,៣៦៤**
- ចំនួនប្រជាជនសរុប ៖ **២២៣ ១៦៦នាក់ ស្រី១០៩ ៧៤៩នាក់**
- ចំនួនគ្រួសារក្រីក្រ១ និង ក្រ២ ៖ **៧ ៧៦០**
- ប្រវែងផ្លូវជនបទដែលបានស្ថាបនា ៖ **៦ គ.ម (សរុបចំនួន ១៣,៣៥ គ.ម)**
- អត្រាទឹកស្អាត ៖ **៧១,៧៦%**
- អត្រាអនាម័យ៖ **៥៩,៨៥%**
- ចំនួនភូមិជនជាតិដើមភាគតិច ៖ **១៨៤ ភូមិ**
- ចំនួនភូមិ(ឈ្មោះភូមិ)ដែលជួបការលំបាកខ្លាំងជាងគេ ៖ **ភូមិអ៊ីទូប និងភូមិបាក់កែ ឃុំវើនសៃ ស្រុកវើនសៃ**

រចនាសម្ព័ន្ធនៃប្រជាជនជាជនជាតិដើមភាគតិចក្នុងឆ្នាំ ២០២១ មានប្រជាជនសរុបចំនួន ១២៦ ០០៥ នាក់ ស្មើនិង ៥៤,៤៦% នៃប្រជាជនសរុប និងមានគ្រួសារសរុបចំនួន ៣១,៥៤៧គ្រួសារ ។ មានការបែងចែកជា ៨ក្រុម/អម្បូរ រួមមាន ព្នង ទំពួន ចារាយ គ្រឹង ការ៉ែត លុន កាចក់ និងព្រៅ ។

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ១.១ ការងាររដ្ឋបាល និងបុគ្គលិក

#### ១.១.១ ស្ថានភាពបុគ្គលិក

- មន្ត្រីសរុបមានចំនួន ២២ នាក់ ប្រុស ១៩ នាក់ និងស្ត្រី ០៣ នាក់ ក្នុងនោះរួមមាន ៖
  - មន្ត្រីនៅបម្រើការងារក្នុងមន្ទីរបច្ចុប្បន្នមាន ចំនួន ២០នាក់ ស្ត្រី ០២នាក់
  - មន្ត្រីកម្មសិក្សា ចំនួន ០០នាក់ ស្ត្រី ០០នាក់
  - មន្ត្រីជាប់កិច្ចសន្យា ចំនួន ០២នាក់ ស្ត្រី ០១នាក់

**១.១.២ ផ្នែកទទួលលិខិតចូលរបស់មន្ទីរ**

- ទទួលលិខិតមកពីបណ្តាស្ថាប័ននានាពីលេខ ០០១ ដល់ ១៦១ ចំនួន ១៦១ លេខ
- ទទួលលិខិតពីក្រសួង និងអង្គភាពក្រោមចំណុះក្រសួងពីលេខ ០០១ ដល់ ០៣៨ ចំនួន ៣៨ លេខ
- លិខិតចូលចំណោះ ៣ លេខ

**១.១.៣ ផ្នែកចុះលិខិតចេញរបស់មន្ទីរ**

**ក. លិខិតចេញទៅតាមបណ្តាអង្គភាពនានាខាងក្រៅមន្ទីរពីលេខ ០០១ ដល់ ២១៩ ចំនួន ២១៩ លេខ**

- លិខិតចេញទៅអង្គភាពនានា ចំនួន ៧១ លេខ
- លិខិតចេញទៅក្រសួង និងនាយកដ្ឋាននានា ចំនួន ៣០ លេខ
- សំណើសុំថវិកា បៀវត្សប្រចាំខែ បុរេប្រទាន ចំនួន ១១៤ លេខ
- សំណើសុំថវិកាសម្រាប់អនុវត្តគម្រោងផ្សេងៗ ចំនួន ០២ លេខ
- លិខិតចេញទៅអង្គការនានា ចំនួន ០២ លេខ

**ខ. លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ពីលេខ ០០១ ដល់ ៣៨៥ ចំនួន ៣៨៥ លេខ**

- លិខិតឧទ្ទេសនាម ចំនួន ៣១ លេខ
- លិខិតបញ្ជាបេសកកម្មមន្ត្រី ចំនួន ១៩២ លេខ
- សំណើសុំលិខិតបញ្ជាបេសកកម្មប្រធានមន្ទីរ ចំនួន ១៨ លេខ
- ដីកាអម ចំនួន ៤៤ លេខ
- លិខិតអនុញ្ញាតច្បាប់ ចំនួន ៧២ លេខ
- លិខិតផ្ទេរសិទ្ធិ ចំនួន ២៤ លេខ
- សេចក្តីសម្រេច ចំនួន ០២ លេខ
- លិខិតបង្គាប់ការ ចំនួន ០៤ លេច

**គ. លិខិតចេញទូទៅ ពី ០០ ដល់ ០០** ចំនួន ០០លេខ

- លិខិតអញ្ជើញ ចំនួន ០០ លេខ

**ឃ.លិខិតចេញទៅក្រសួង និងបណ្តាអង្គភាពនានា ក្រោមឱវាទមន្ទីរ ពីលេខ ០០១ដល់០៥៧ ចំនួន ៥៧ លេខ**

- របាយការណ៍របស់មន្ទីរ ចំនួន ៥៧ លេខ

**១.២. ការងារផែនការ**

- បានបញ្ចប់ការបញ្ចូលទិន្នន័យ សម្រាប់ជាធាតុចូលក្នុងការធ្វើគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ១០ឆ្នាំ (២០២១-២០៣០) របស់ក្រសួងអភិវឌ្ឍន៍ជនបទ

- បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំគម្រោងវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៣-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ (តាមប្រព័ន្ធអនឡាញ)
- បានចូលរួមគាំទ្រកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត រតនគិរី ដែលមានគម្រោងដូចជា៖ ការជួសជុលអណ្តូង, ការសាងសង់អណ្តូងថ្មី, ការពង្រឹងសមត្ថភាព ក្រុមអ្នក ប្រើប្រាស់ទឹក និងការទុកដាក់ទឹកប្រកបដោយសុវត្ថិភាព, ការថែទាំផ្លូវជនបទជាលក្ខណខួប, ការថែទាំផ្លូវជនបទទប់ទល់និងអាកាសធាតុ, ការពង្រឹងសមត្ថភាព និងធ្វើបច្ចុប្បន្នភាព គ.អ.ភ ការពង្រឹងសមត្ថភាព និងធ្វើបច្ចុប្បន្នភាព គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច
- បានចុះតាមដានការអនុវត្តថវិកាកម្មវិធីចំនួន ១២លើក
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី គោលការណ៍ណែនាំពីការរៀបចំថវិកា សមិទ្ធកម្ម និងការសរសេរសូចនាករសមិទ្ធកម្ម រយៈពេល២ថ្ងៃ នៅខេត្តសៀមរាប ដែលរៀបចំឡើងដោយនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ដែលមានអ្នកចូលរួមសរុបចំនួន ៧៤នាក់ ស្រី ១៣នាក់។ អ្នកចូលរួមមានដូចជា ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ និងមន្ត្រីទទួលបន្ទុកផែនការ និងមន្ត្រីនៃការិយាល័យនានា របស់មន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១៣ រាជធានី ខេត្ត។
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តព្រះសីហនុ រយៈពេល១ថ្ងៃ រៀបចំដោយនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ដែលមានអ្នកចូលរួមមកពីនាយកដ្ឋាន និងមន្ទីរចំនួន ២៥រាជធានី-ខេត្ត សរុបចំនួន ៧៥នាក់ ស្រី ១៥នាក់
- បានដាក់ជូននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នូវផែនការយុទ្ធសាស្ត្រថវិកា ២០២៣-២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ ២០២៣
- បានសរសេររបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដាក់ជូននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ រដ្ឋបាលខេត្ត និងក្រុមប្រឹក្សាខេត្តរតនគិរី

### ១.៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

- **កម្មវិធីចំណាយ (អនុកម្មវិធី និងចង្កោមសកម្មភាពតាមអង្គភាពនីមួយៗ)**
  - បានរៀបចំផែនការថវិកា ផែនការលទ្ធកម្ម របាយការណ៍ចំណូលនិងចំណាយ របាយការណ៍លទ្ធកម្ម ជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំ
  - បានរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ
  - បានផ្គត់ផ្គង់ និងបើកផ្តល់ប្រាក់បៀវត្ស ជូនបុគ្គលិកមន្ត្រីរាជការ និងកិច្ចសន្យា ចំនួន ២ដងក្នុង១ ខែ (១២ខែ)
  - បានរៀបចំ និងទូទាត់ រដ្ឋទេយ្យបុរេប្រទាន អគ្គិសនី សោហ៊ុយទូរគមនាគមន៍ បង់ពន្ធរថយន្ត និងចំណាយផ្សេងៗ។
- **ផែនការលទ្ធកម្ម និងការទូទាត់ របស់មន្ទីរ**
  - ជួសជុលផ្លូវក្រាលក្រួសក្រហមពីភូមិសាយ៉ស់ ឃុំកាឡែង ទៅភូមិអ៊ុល ឃុំបាតាង ស្រុកលំផាត់ ខេត្តរតនគិរី ប្រវែង ២ ០០០ម៉ែត្រ សម្រាប់ឆ្នាំ២០២២ (ទូទាត់រួចរាល់ ១០០%)

- ការងារជួសជុលរបងចំហៀងខាងលិច និងក្រាលការ៉ូ ការ៉ូឡា (ទូទាត់រួចរាល់១០០%)
- សម្ភារៈនិងបរិក្ខារបច្ចេកទេសព័តមានវិទ្យា (ទូទាត់រួចរាល់ ១០០%)
- សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនព័តមានវិទ្យា (ទូទាត់រួចរាល់ ១០០%)
- ប្រេងឥន្ធនៈ និងប្រេងរំអិល (ទូទាត់រួចរាល់ ១០០%)
- គ្រឿងសង្ហារឹម (ទូទាត់រួចរាល់ ១០០%)
- ទិញសម្ភារៈការិយាល័យ (ទូទាត់រួចរាល់ ១០០%)
- សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ (ទូទាត់រួចរាល់ ១០០%)
- ពូជ និងកូនរុក្ខជាតិ (ទូទាត់រួចរាល់ ១០០%)
- ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន (ទូទាត់រួចរាល់ ១០០%)
- ការថែទាំបណ្តាញផ្សេងៗ (ទូទាត់រួចរាល់ ១០០%)
- ការថែទាំ និងជួសជុលឧបករណ៍បច្ចេកទេស (ទូទាត់រួចរាល់ ១០០%)

• **ការទូទាត់ថវិកា ការងាររបស់ក្រសួង**

- ជួសជុលផ្លូវបន្ទាន់ក្រាលក្រួសក្រហម និងល្បាយថ្មភ្នំ ចំនួន ០៣កំណាត់ ប្រវែង ៣គ.ម ទទឹងខ្នងលើ ៦ម៉ែត្រ កម្រាស់ ១៥សង់ទីម៉ែត្រ ស្ថិតនៅភូមិពាក់ ឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី (ទូទាត់រួចរាល់ ១០០%)
- ជួសជុលផ្លូវខួបក្រាលក្រួសក្រហម ចំនួន ០១ខ្សែ ប្រវែង ១២.៥គ.ម ទទឹងខ្នងលើ ៥ម៉ែត្រ កម្រាស់ ០,២ម៉ែត្រ ស្ថិតនៅភូមិប៉ក់ធំ ភូមិប៉ក់តូច និងភូមិឡំ ឃុំប៉ក់ញ៉ៃ ស្រុក អូរយ៉ាដាវ ខេត្តរតនគិរី (ទូទាត់រួចរាល់ ៤០%)
- ជួសជុលផ្លូវប្រចាំក្រាលក្រួសក្រហម ចំនួន៧ខ្សែ ប្រវែងសរុប ៩៦.២គ.ម ទទឹងខ្នងលើ ៥ម៉ែត្រ ៦ម៉ែត្រ និង៧ម៉ែត្រ ស្ថិតនៅឃុំកាចូន ឃុំបរខាំ ឃុំបាតាង ឃុំកាឡែង ឃុំតាអង ឃុំតឺន ឃុំត្រពាំងច្រេស ឃុំកោះពាក្យ ឃុំប៉ុង ឃុំភ្នំកុក ឃុំល្បាំង២ សង្កាត់យក្ខឡោម សង្កាត់កាចាញ ស្រុកអូរយ៉ាដាវ ស្រុកវើនសៃ ស្រុកលំផាត់ ស្រុកកូនមុំ ក្រុងបានលុង ខេត្តរតនគិរី គម្រោងផែនការឆ្នាំ២០២២ (ទូទាត់រួចរាល់ ៤០%)
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេហ្វចំនួន ០៤អណ្តូង និងសាងសង់អាងត្រងទឹកភ្លៀង ចំណុះ៤ម៉ែត្រគូប ចំនួន ២៩អាង ស្ថិតនៅស្រុកកូនមុំ ខេត្តរតនគិរី (ទូទាត់រួចរាល់ ៤០%)។

• **របាយការណ៍ចំណាយថវិកាតាមជំពូករបស់មន្ទីរ**

- ថវិកា ដែរទទួលបានសម្រាប់ឆ្នាំ២០២២ = ១ ៣៦៤ ៦០០ ០០០ រៀល
    - ➢ ជំពូក ៦០ = ២០៥ ៣០០ ០០០ រៀល
    - ➢ ជំពូក ៦១ = ៧៣២ ២០០ ០០០ រៀល
    - ➢ ជំពូក ៦៣ = ២ ០០០ ០០០ រៀល
    - ➢ ជំពូក ៦៤ = ៤២៥ ១០០ ០០០ រៀល
- ថវិកា ដែលបានអនុវត្ត សម្រាប់ឆ្នាំ២០២២ = ១ ៣៣៧ ៥៦៥ ៦០០ រៀល

- ដំពូក ៦០ = ២០១ ៣០៤ ២០០ រៀល
- ដំពូក ៦១ = ៧៣០ ០៥១ ៤០០ រៀល
- ដំពូក ៦៣ = ២០០ ០០០ រៀល
- ដំពូក ៦៤ = ៤០៦ ០១០ ០០០ រៀល

**១.៤. ការងារសវនកម្ម**

- សាវនកម្មជាតិ សវនកម្មផ្ទៃក្នុង អគាធិការដ្ឋាន បានចុះមកពិនិត្យឯកសារចំណូល ចំណាយ លទ្ធកម្ម កើន ថយ សារពើភណ្ឌទ្រព្យរដ្ឋនិងការងាររដ្ឋបាល ក្នុងឆ្នាំ ២០២១ បានចំនួន ១លើក ក្នុង ១ស្ថាប័ន

**១.៥. ការងារអធិការកិច្ច**

- អធិការកិច្ច ក្រសួងទំនាក់ទំនងរដ្ឋសភា និងអធិការកិច្ច បានចុះមកពិនិត្យមើលឯកសារលទ្ធកម្ម ក្រោមសិទ្ធសម្រេច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចំណូល ចំណាយ ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**២.១ ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- បានធ្វើបច្ចុប្បន្នភាពផ្លូវជនបទ ចំនួន ០៥ ខ្សែ មានប្រវែងសរុប ៣០,៨គ.ម មានទីតាំងដូចខាងក្រោម៖
  - **ខ្សែទី១:** ពីផ្លូវខេត្តលេខ ៣៧៨៩ ត្រង់ភូមិប៉ាអរ ចូលទៅកាន់ភូមិជ្រុង ឃុំកិះចុង ស្រុកបរកែវ មានប្រវែង ២,៣គ.ម។
  - **ខ្សែទី២:** ពីភូមិជ្រុង ចូលទៅកាន់ភូមិទៀន ភូមិរ៉យ ឃុំកិះចុង ស្រុកបរកែវ និងឆ្លោះទៅកាន់ភូមិបរញ៉ុក ឃុំសាមគ្គី ស្រុកអូរជុំ មានប្រវែង ១៥,៩គ.ម ។
  - **ខ្សែទី៣:** ពីភូមិបរញ៉ុក ចូលទៅកាន់ភូមិកាម៉ែន ឃុំសាមគ្គី ស្រុកអូរជុំ មានប្រវែង ៥,៤គ.ម។
  - **ខ្សែទី៤:** ផ្លូវភូមិប៉ាកាឡាន់-វើនសៃ មានប្រវែង ៤.៩គ.ម ស្ថិតនៅភូមិប៉ាកាឡាន់ ឃុំប៉ាកាឡាន់ និងភូមិវើនសៃ ឃុំវើនសៃ ស្រុកវើនសៃ។
  - **ខ្សែទី៥:** ផ្លូវភូមិប៉ាកាឡាន់-កំពង់ចាម មានប្រវែង ៥.៣គ.ម ស្ថិតនៅភូមិប៉ាកាឡាន់ និងភូមិកំពង់ចាម ឃុំប៉ាកាឡាន់ ស្រុកវើនសៃ។

**២.២ ការងាររាប់ចំនួនចរាចរណ៍**

- បានរាប់ចំនួនចរាចរណ៍ នៅលើផ្លូវលំជនបទចំនួន ០៥ ខ្សែ មានប្រវែងសរុប ៩០ គ.ម មានទីតាំងដូចខាងក្រោម៖
  - **ខ្សែទី១:** ពីផ្លូវជាតិលេខ ៧៨ ត្រង់ភូមិត្រុំ ឃុំឡាមីញ ចូលទៅកាន់ភូមិយ៉ែម ឃុំស៊ើង និងភូមិជ្រាក ឃុំលុងឃុង ស្រុកបរកែវ និងឆ្លោះទៅកាន់ ភូមិណងហៃ ឃុំសេដា ស្រុកលំផាត់ មានប្រវែង ១៥.៨គ.ម។
  - **ខ្សែទី២:** ពីផ្លូវជាតិលេខ ៧៦ ត្រង់ភូមិព្រួក ចូលទៅកាន់ភូមិបាតាង ឃុំបាតាង និងឆ្លោះទៅកាន់ជំរុំបីស្រុក ត្រង់ភូមិសាយ៉ស់ ឃុំកាឡែង ស្រុកលំផាត់ មានប្រវែង ១៧,៤ គ.ម។

- **ខ្សែទី៣:** ពីផ្សាររវៀនសៃ ត្រង់ភូមិបានហ្វាំង ឃុំប៉ុង ចូលទៅកាន់ភូមិភ្នំកុកឡាវ ភូមិភ្នំកុកព្រៅ និងឆ្ពោះទៅកាន់ ភូមិទៀមក្រោម ឃុំភ្នំកុក ស្រុកវើនសៃ មានប្រវែង ១៧,៥គ.ម។
- **ខ្សែទី៤:** ពីភូមិសមុទ្រក្រោម ចូលទៅកាន់ភូមិកែងសាន់ ឃុំសេដា ស្រុកលំផាត់ មានប្រវែង ២២,៣គ.ម។
- **ខ្សែទី៥:** ពីផ្លូវជាតិលេខ ៧៨ ត្រង់ភូមិប៉ក់ធំ ចូលទៅកាន់ភូមិប៉ក់តូច និងឆ្ពោះទៅកាន់ភូមិឡុំ ទៅទល់នឹងព្រំប្រទល់ប្រទេសវៀតណាម ស្ថិតនៅឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ មានប្រវែង ១៧ គ.ម។

ផ្លូវទាំង ៥ខ្សែ នេះមានចរាចរណ៍សរុបដូចខាងក្រោម៖

- អ្នកដើរ/ថ្មើរជើង ១៧០ នាក់
- មធ្យោបាយផ្សេងៗអត់ម៉ាស៊ីន ០០ គ្រឿង
- កង់ឆ្លងកាត់ ៦៩ ជើង
- ម៉ូតូរ៉ឺ ម៉ូតូកង់បីឆ្លងកាត់ ២ ៨៩៦ គ្រឿង
- ត្រាក់ទ័រ រឺ គោយន្តឆ្លងកាត់ ៤៨ គ្រឿង
- ឡានតូច ឆ្លងកាត់ ១៦៩ គ្រឿង
- ឡានក្រុងធន់ធ្ងន់ធំជាង ២៥ កៅអី ០៧ គ្រឿង
- ឡានក្រុងធន់តូចតិចជាង ២៥ កៅអី ២៨ គ្រឿង
- ឡានដឹកទំនិញ ឡានដឹកដី និងឡានធំ ១៩៨ គ្រឿង

## ២.៣ ការងារអភិវឌ្ឍផ្លូវជនបទ

- បានចុះសិក្សាផ្លូវចំនួន ៧ ខ្សែ មានប្រវែងសរុប ១៥១,៧គ.ម
  - **ទី១៖** ១ ខ្សែ មានប្រវែង ១៦,១គ.ម ចេញពីផ្លូវជាតិលេខ៧៨ ត្រង់ភូមិ៣ (អូរភ្លូង) ឃុំត្រពាំងច្រេស ចូលទៅកាន់ភូមិស្រែពកតូច ឃុំសិរីមង្គល ស្រុកកូនមុំ។
  - **ទី២៖** ១ខ្សែ មានប្រវែង ២៤,៦គ.ម ចេញពីផ្លូវជាតិលេខ៧៦ ត្រង់ភូមិដីឡូតិ៍ ឃុំជ័យឧត្តម ចូលទៅកាន់ភូមិលំផាត់ ភូមិអូរកាន ភូមិសាមខា ឃុំជ័យឧត្តម ស្រុកលំផាត់ និងឆ្ពោះទៅកាន់ភូមិនាងដី ភូមិស្រែពកតូច ភូមិស្រែពកធំ ឃុំសិរីមង្គល ស្រុកកូនមុំ។
  - **ទី៣៖** ១ ខ្សែ មានប្រវែង ៣៨,៣គ.ម ចេញពីផ្លូវជាតិលេខ ៧៨ ត្រង់ភូមិ៤ ចូលទៅកាន់ភូមិ៣ សង្កាត់កាចាញ ក្រុងបានលុង ភូមិចាអ៊ុងកេត ភូមិចាអ៊ុងចាន់ ភូមិចាអ៊ុងកៅ ឃុំចាអ៊ុង ស្រុកអូរជុំ និងឆ្ពោះទៅកាន់ភូមិហាត់ប៉ក់ ឃុំហាត់ប៉ក់ ស្រុកវើនសៃ។
  - **ទី៤៖** ០១ ខ្សែ មានប្រវែង ៤,៤គ.ម ចេញពីភូមិឃឹន ឃុំកក់ ស្រុកបរកែវ ភ្ជាប់ទៅកាន់ភូមិកាម៉ែន ឃុំសាមគ្គី ស្រុកអូរជុំ។
  - **ទី៥៖** ០១ ខ្សែ មានប្រវែង ២៦,១គ.ម ចេញពីផ្លូវជាតិលេខ ៧៨ ត្រង់ភូមិពាក់ ចូលទៅកាន់ភូមិទេនសុស ភូមិតេនង៉ល និងឆ្ពោះទៅកាន់ភូមិដរ ឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ។
  - **ទី៦៖** ០៧ ខ្សែ មានប្រវែង ១៩,៥គ.ម ស្ថិតនៅស្រុកអូរយ៉ាដាវ ស្រុកបរកែវ ស្រុកអូរជុំ ស្រុកកូនមុំ និងស្រុកលំផាត់។
  - **ទី៧៖** ១ខ្សែ មានប្រវែង ១,៨គ.ម ស្ថិតនៅភូមិពាក់ឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ។

### ២.៤ ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ

- បានដាំគ្រាប់ត្នោតសងខាងផ្លូវជនបទចំនួន ១០ ០០០ គ្រាប់ ក្នុងភូមិរ៉ង ភូមិវ៉ាយ ឃុំកាចូន ស្រុកវើនសៃ។

### ២.៥ ការងារជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ

- បានបញ្ចប់ការជួសជុល ថែទាំផ្លូវចំនួន ១១ ខ្សែ មានប្រវែងសរុប ១២៨ គ.ម
  - **ទី១៖** ០១ខ្សែ មានប្រវែង ១៤,៣គម ស្ថិតនៅឃុំឡាមីញ ត្រង់ភូមិត្រុំ ចេញពីផ្លូវជាតិលេខ ៧៨ ចូលទៅកាន់ភូមិយ៉ែម ឃុំសើុង និងភូមិជ្រាក ឃុំលុងឃុង ស្រុកបរកែវ ឆ្ពោះទៅកាន់ភូមិណងហៃ ឃុំសេដា ស្រុកលំផាត់។
  - **ទី២៖** ០១ ខ្សែ ប្រវែង ២គ.ម ស្ថិតនៅភូមិសាយ៉ស់ ឃុំកាឡែង ស្រុកលំផាត់ ដោយប្រើប្រាស់ថវិកាកម្មវិធី ឆ្នាំ២០២២ របស់មន្ទីរ។
  - **ទី៣៖** ០១ ខ្សែ ប្រវែង ៣ គ.ម ក្រាលក្រួសក្រហម និងល្បាយថ្មភ្នំ ចេញពីផ្លូវជាតិលេខ ៧៨ ត្រង់ភូមិពាក់ ចូលទៅកាន់ភូមិទេនសុស ភូមិតេនង៉ល និងភូមិជរ ឃុំយ៉ាទុង ស្រុក អូរយ៉ាដាវ ។
  - **ទី៤៖** ០១ ខ្សែ មានប្រវែង ១២,៥គម ស្ថិតនៅភូមិប៉ក់ធំ ចេញពីផ្លូវជាតិលេខ ៧៨ ចូលទៅកាន់ភូមិប៉ក់តូច និងឆ្ពោះទៅកាន់ភូមិឡុំ ឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ។
  - **ទី៥៖** ០១ ខ្សែ មានប្រវែង ១៧,២គ.ម ស្ថិតនៅឃុំបរខាំ ស្រុកអូរយ៉ាដាវ។
  - **ទី៦៖** ០១ ខ្សែ មានប្រវែង ១២គ.ម ពីរមណីយដ្ឋានបឹងយក្ខឡោម ត្រង់ភូមិឡូន សង្កាត់យក្ខឡោម ក្រុងបានលុង ចូលទៅកាន់ ភូមិចង់រ៉ា ឃុំបាតាង ស្រុកលំផាត់។
  - **ទី៧៖** ០១ ខ្សែ មានប្រវែង ២១,៣គ.ម ពីផ្លូវជាតិលេខ ៧៨ ភូមិទុស ឃុំតាងអង ចូលទៅកាន់ ភូមិតឺន ភូមិកាំបាក់ ភូមិឡាអ៊ីន ឃុំតឺន ឆ្ពោះទៅកាន់ភូមិបួន (គ៦០) ឃុំត្រពាំងច្រេស ស្រុកកូនមុំ។
  - **ទី៨៖** ០១ ខ្សែ មានប្រវែង ១៧,៣គ.ម ស្ថិតនៅឃុំកាចូន និងឃុំកោះពាក្យ ស្រុកវើនសៃ។
  - **ទី៩៖** ០១ ខ្សែ មានប្រវែង ១៧,៥គ.ម ស្ថិតនៅឃុំប៉ុង និងឃុំភ្នំកុក ស្រុកវើនសៃ។
  - **ទី១០៖** ០១ ខ្សែ មានប្រវែង ៤,៧គ.ម ស្ថិតនៅសង្កាត់កាចាញ ក្រុងបានលុង និងឃុំល្បាំង២ ស្រុកលំផាត់
  - **ទី១១៖** ១ ខ្សែ មានប្រវែង ៦,២គ.ម ពីភូមិអូររមៀត សង្កាត់ឡាបានសៀក ចូលទៅកាន់ភូមិពីរ សង្កាត់កាចាញ និងឆ្ពោះទៅកាន់ភូមិឡូន សង្កាត់យក្ខឡោម ក្រុងបានលុង។

## ៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

### ៣.១ ការងារសាងសង់អណ្តូងទឹក ប្រភពទឹក និងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ជនបទចម្រុះ

- ការងារផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ តាមសហគមន៍សម្រេចបានក្នុងឆ្នាំ ២០២២ ស្មើនឹង ៧១,៧៦% ដែលមាន អត្រាកំណើន ៧,៥៦% ធៀបនិងឆ្នាំ ២០២១។
- បានសាងសង់អណ្តូងស្នប់ (Afridev) ចំនួន ៤ នៅភូមិស្រែពកធំ ១អណ្តូង, ភូមិស្រែពកតូច២ អណ្តូង (ក្នុងឃុំសិរីមង្គល ស្រុកកូនមុំ) និង ១អណ្តូងនៅភូមិសាយ៉ស់ (ស្រែ) ឃុំកាឡែង ស្រុកលំផាត់ មានអ្នកទទួលផលចំនួន១០៧គ្រួសារ ស្មើនឹង ៥៣៧នាក់ ស្រី២៨១នាក់

កុមារ ១២២នាក់ និងបានចងក្រងក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ នៅទីតាំងអណ្តូងទាំង ៤ នោះផងដែរ។

- បានសងសង់អាងត្រងទឹកភ្លៀងចំណុះ៤ម៉ែត្រគូប ចំនួន ២៩អាង ក្នុងភូមិស្រែពកធំ ឃុំសិរីមង្គល ស្រុកកូនមុំ ដែលមានអ្នកទទួលផលសរុប ៦៣គ្រួសារ ស្មើនឹង ២៧៥នាក់ ស្រី ១៣៧នាក់ កុមារ ៤៥នាក់។
- បានធ្វើពិសោធន៍គុណភាពទឹក ចំនួន ៣១សំណាក/អណ្តូង ដែលយកមកពីចំនួន ២ខេត្ត (ខេត្តរតនគិរី ២៦សំណាក/អណ្តូង និងខេត្តស្ទឹងត្រែង ៥សំណាក/អណ្តូង

**៣.២. ការងារថែទាំ និងជួសជុលអណ្តូងទឹកស្អាតជនបទ**

- ជួសជុលអណ្តូងស្នប់ (Afridev) ចំនួន ២៥អណ្តូង ក្នុងឃុំភ្នំកុក ឃុំប៉ុង និងឃុំកាចូន ស្រុកវើនសៃ។ មានអ្នកទទួលផល សរុប ៤៨៦គ្រួសារ មនុស្សសរុបចំនួន ២៣៧៦ នាក់ ស្រីចំនួន ១២៤១ នាក់ និងកុមារសរុបចំនួន ៣៦២នាក់។

**៣.៣. ការងារបណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹកនៅជនបទដល់សហគមន៍ប្រើប្រាស់ទឹក**

- បានបើកវគ្គបណ្តុះបណ្តាលពីបច្ចេកទេស ដាក់ក្លរសម្លាប់មេរោគ ក្នុងទឹកដល់គណៈ កម្មការស្ថានីយទឹកស្អាតអូរកាននិង ស្ថានីទឹកស្អាតស្រែពកតូច ដែលមានអ្នកចូលរួមសរុប ១៦នាក់ ស្រ្តី ៥នាក់ នៅក្នុងភូមិអូរកាន ឃុំជ័យឧត្តម ស្រុកលំផាត់។

**៣.៤ ការងារអប់រំប្រជាពលរដ្ឋ អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត**

- បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីមណ្ឌលសុខភាពចំនួន២៥មណ្ឌលទូទាំងខេត្ត ស្តីពីទឹកស្អាត នឹងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់លើសុខភាព មានអ្នកចូលរួម ៤០នាក់ ស្រ្តី ០៥នាក់។
- បានបើកវគ្គបណ្តុះបណ្តាលដល់ក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ ពីតួនាទីភារៈកិច្ចការជួសជុលថែទាំអណ្តូងស្នប់ និងការទុកដាក់ទឹកប្រកបដោយសុវត្ថិភាពចំនួន០៤វគ្គ មានអ្នកចូលរួមសរុប ១៣១នាក់ ស្រ្តី ២៣នាក់ មកពី១៥ភូមិ ក្នុងឃុំជ័យឧត្តម ស្រុកលំផាត់ និងឃុំភ្នំកុក ឃុំកាចូន និងឃុំប៉ុង ស្រុកវើនសៃ ។

**៣.៥ ការងារស្រង់ទិន្នន័យបង្គន់អនាម័យជនបទ**

- ទូទាំងខេត្តរតនគិរី មានខ្នងផ្ទះសរុបចំនួន ៣៩,៣៦៣ខ្នង និងខ្នងផ្ទះមានបង្គន់សរុបចំនួន ២៣,៧៥១បង្គន់។
- អត្រាគ្របដណ្តប់អនាម័យទូទាំងខេត្ត សម្រេចបាន ៦០,៣៣% ដែលមានអត្រាកំណើនប្រមាណជា ៣% ធៀបនិងឆ្នាំ២០២០ មាន ៥៧%។

**៣.៦ ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ ឲ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- បណ្តុះបណ្តាល ពីការធ្វើអនាម័យលើប្រធានបទ ផឹកទឹកដាំពុះ លាងដៃជាមួយសាប៊ូ និង ការប្រើប្រាស់បង្គន់ បានចំនួន ៣វគ្គ (ឃុំកោះពាក្យ ឃុំប៉ាកាឡាន់ និងឃុំភ្នំកុក ស្រុកវើនសៃ) មានអ្នកចូលរួមចំនួន ១១៩ នាក់ ស្រី ៥៨នាក់។

## ៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

### ៤.១ ការងារអភិវឌ្ឍន៍សហគមន៍

- បានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ០៧ វគ្គ ក្នុងស្រុកវើនសៃ ឃុំចំនួន ០៧ មានភូមិចំនួន ២៩ ភូមិដែលមានសមាជិក គ.អ.ភ ចូលរួមសរុបចំនួន ២០៣នាក់ ស្រីចំនួន ៥២នាក់។
- ធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន ០៦ ក្រុង/ស្រុក ២០ សង្កាត់/ឃុំ ៩៣ភូមិ មាន គ.អ.ភ សរុបចំនួន ៧២១ នាក់ ស្រី ១៦៦នាក់។ គ.អ.ភ ផ្លាស់ប្តូរសរុបចំនួន ១០៣នាក់ ស្រីចំនួន ២០នាក់ ។ គ.អ.ភ ស្លាប់សរុបចំនួន ០៩នាក់ ។
- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិចំនួន ២៣ភូមិបានចលនាគៀគរថវិកាពីគ្រួសារក្នុងភូមិ និងសប្បុរសជននានាបានចំនួន ៣៩,៨៣០,០០០ លានរៀល ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ភូមិរបស់ពួកគេមានដូចតទៅ៖
    ១. ធ្វើផ្លូវដីក្នុងភូមិ ១ខ្សែ
    ២. ជួសជុលផ្លូវដីក្នុងភូមិចំនួន ១១ខ្សែ
    ៣. ជួសជុលស្ពានឈើ ៥កន្លែង
    ៤. ដាក់លូកាត់ផ្លូវ ១កន្លែង
    ៥. ធ្វើអនាម័យក្នុងភូមិ ៦លើក
    ៦. ធ្វើប្រព័ន្ធចែកចាយទឹកក្នុងភូមិ ១កន្លែង

### ៤.២ ការងារអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច

- បានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ពីតួនាទីភារៈកិច្ចរបស់គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចចំនួន០៦ ភូមិ នៅភូមិឆ្វយអំពិល និងភូមិឆ្វយទុំ ឃុំចាអ៊ុង ភូមិល្មីនជង ឃុំអូរជុំ ស្រុកអូរជុំ និងភូមិកាំផ្លិញ ភូមិកាលង និងភូមិកាទៀង ឃុំល្បាំង១ ស្រុកលំផាត់ មានអ្នកចូលរួមសរុប ១០៩ នាក់ស្រី ៣៦ នាក់ ។
- បានចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចបាន ១៤ភូមិ ភូមិតាង៉ា ភូមិពែង ភូមិមុយ ភូមិតាំងសេ ភូមិកាជូត ភូមិញ៉ាង ឃុំញ៉ាង ស្រុកអណ្តូងមាស ភូមិរ៉ក់ ភូមិឡាឡៃ ឃុំកុកឡាក់ ស្រុកវើនសៃ ភូមិទុន ភូមិទំពួនរឹងធំ ឃុំតាវែងក្រោម ស្រុកតាវែង ភូមិខ្មែង ភូមិកាន់ឈើង ភូមិកងកុយ ភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ។ មានសមាជិកគណៈកម្មាធិកាសហគមន៍សរុប ១២៦នាក់ ស្រី ៣១ នាក់ ដែលក្នុងនោះមានការផ្លាស់ប្តូរសមាជិកចំនួន ២៦នាក់ ។
- បានចូលរួមសម្របសម្រួលកិច្ចប្រជុំ ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច កាចក់ នៅភូមិអ៊ិន ឃុំតាឡាវ ស្រុកអណ្តូងមាស។ ដែលមានអ្នកចូលរួមសរុប ៦៨នាក់ ស្រី ៣៨ នាក់។

## ៥.សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ

### ៥.១ ការងារសហប្រតិបត្តិការជាមួយគម្រោងដៃគូអន្តរជាតិ

- សាងសង់អណ្តូងក្នុងមតេយ្យសហគមន៍ ចំនួន ៣ អណ្តូង នៅភូមិពីរ ឃុំល្អក់ ភូមិអូម និង ភូមិប៉ាអរ ឃុំឯកភាព ស្រុកអូរជុំ

- សាងសង់អណ្តូងមណ្ឌលសុខភាព ចំនួន ៣ អណ្តូង នៅស្រុករវៀនសៃ ស្រុកបរកែវ ស្រុកអណ្តូងមាស
- សាងសង់បង្គន់ក្នុងមតេយ្យសហគមន៍ចំនួន ១០ បង្គន់ ឃុំឯកភាព, ឃុំប៉ូយ ស្រុកអូរជុំ និងឃុំតាវែងលើ, ឃុំតាវែងក្រោម ស្រុកតាវែង
- សាងសង់បង្គន់ក្នុងមណ្ឌលសុខភាពចំនួន ៣ បង្គន់ នៅស្រុកអូរជុំ ស្រុករវៀនសៃ ស្រុកបរកែវ
- សាងសង់ប្រព័ន្ធទឹកក្នុងសាលាមតេយ្យសហគមន៍ចំនួន ៧ ប្រព័ន្ធ ឃុំតាវែងលើ និងឃុំតាវែងក្រោម ស្រុកតាវែង
- សាងសង់ប្រព័ន្ធចែកចាយទឹកតាមទុយោនៅតាមសហគមន៍ចំនួន ៤ (ស្រុករវៀនសៃ ២ ស្រុកតាវែង ១ និងស្រុកអណ្តូងមាស ១)
- ផ្តល់បង្គន់បដិភាគដល់គ្រួសារក្រីក្រចំនួន ១២៩ បង្គន់ ស្រុករវៀនសៃ ស្រុកតាវែង និងស្រុក អណ្តូងមាស។

## II. បញ្ហាប្រឈម

- ប្រជាពលរដ្ឋ មិនទាន់មានភាពជាម្ចាស់លើសមិទ្ធិផលដែលមានក្នុងសហគមន៍របស់ពួកគេ
- តំបន់ដាច់ស្រយាលមួយចំនួន មិនទាន់មានទឹកស្អាតប្រើប្រាស់ និងអនាម័យគ្រប់គ្រាន់។
- ផ្លូវជនបទដែលបានជួសជុលរួច រងការខូចដោយជំនន់ទឹកភ្លៀង និងរថយន្តធំៗមួយចំនួនដឹកលើសទំងន់។
- គ្រួសារមួយចំនួនមិនចាប់អារម្មណ៍ ឬពន្យាពេលក្នុងការសាងសង់បង្គន់អនាម័យ
- មានសំណូមពរតាមភូមិពីប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈរបស់ក្រុមប្រឹក្សាខេត្តអោយមន្ទីរអភិវឌ្ឍន៍ជនបទ ជួយពួកគាត់ក្នុងការផ្តល់ផ្លូវ-ស្ពាន (ផ្លូវបេតុង និងផ្លូវកៅស៊ូ) ទឹកស្អាត និងបង្គន់អនាម័យ
- ថវិកាប្រចាំឆ្នាំរបស់មន្ទីរសម្រាប់អនុវត្តសកម្មភាព មិនទាន់ឆ្លើយតបនិងតម្រូវការរបស់ប្រជាពលរដ្ឋ។

## III. ទិសដៅការងារឆ្នាំ ២០២៣

- ជួសជុលផ្លូវក្រាលគ្រួសក្រហម ១ខ្សែ ប្រវែង ២ ០០០ ម៉ែត្រ នៅភូមិណងហៃ ឃុំសេដា ស្រុកលំផាត់
- ការថែទាំផ្លូវទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ (ដាំគ្រាប់ត្នោត) ចំនួន ១០ ០០០ គ្រាប់ នៅឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ
- បំផុសអនាម័យអំពីការលាងដៃជាមួយសាប៊ូ ផឹកទឹកដាំពុះ និងប្រើប្រាស់បង្គន់ ចំនួន ៣វគ្គ នៅឃុំត្រពាំងក្រហម ឃុំត្រពាំងច្រេស ឃុំ តឺន ស្រុកកូនមុំ
- ផ្សព្វផ្សាយពីរបៀប ទុកដាក់ បរិភោគ ដែលមានសុវត្ថិភាព និង ពង្រឹងសមត្ថភាពក្រុមអ្នកប្រើប្រាស់ទឹកស្អាត (O&M) ចំនួន ៣វគ្គ នៅឃុំតាឡាវ ឃុំញ៉ាង ឃុំម៉ាលិក ស្រុកអណ្តូងមាស
- បណ្តុះបណ្តាលពីតួនាទី និងភារៈកិច្ចគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ចំនួន ៦វគ្គ នៅភូមិរ៉ក ភូមិឡាឡៃ ភូមិតាំសេ ភូមិដាល ភូមិទុន និងភូមិទំពួនរឹងធំ

- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ៣ លើក នៅភូមិកងណាក ឃុំវើនសៃ ភូមិត្រាក ភូមិឡាមីយ ឃុំកុឡាក់
- បច្ចុប្បន្នភាពគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ១៦ភូមិ នៅ (ភូមិសាលា ភូមិកក់  ភូមិស៊ូ ភូមិយ៉ាសោម ភូមិទៀន ភូមិប៉ាអរ ភូមិគ្រៀង ភូមិជ្រុង ភូមិប៉ាងគិត ភូមិចាន់ ភូមិគិគួង ភូមិរៀងវិញ ភូមិផ្យ៉ាង ភូមិសៀងសាយ ភូមិតាង៉ាច និងភូមិផាវ)
- បណ្តុះបណ្តាលតួនាទី និងភារកិច្ច គ.អ.ភ ៧ វគ្គ នៅ (ឃុំប៉ាកាឡាន់ ឃុំហាត់ប៉ក់ ស្រុកវើនសៃ ឃុំកាឡែង ស្រុកលំផាត់, ឃុំលំជ័រ ឃុំសោមធំ ឃុំប៉ក់ញ៉ៃ ឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ)
- ធ្វើបច្ចុប្បន្នភាព (គ.អ.ភ) ៦៦ ភូមិ (ក្នុងឃុំសិរីមង្គល ឃុំតាអង ឃុំតឺន ឃុំអូរជុំ ឃុំសាមគ្គី ឃុំ ឯកភាព ឃុំចាអ៊ុង ឃុំល្អក់ ឃុំប៉ូយ ឃុំកាឡែ ឃុំសេដា សង្កាត់ឡាបានសៀក សង្កាត់បឹងកន្សែង)
- តាមដានការអនុវត្តថវិកាកម្មវិធីតាមការិយាល័យជំនាញចំនួន ១២លើក។

**សេចក្តីសន្និដ្ឋាន**

ប្រជាពលរដ្ឋនៅទីជនបទខេត្តរតនគិរី បានទទួលការអភិវឌ្ឍន៍តិចតួចនៅឡើយ ដូចជាផ្លូវថ្នល់ ទឹកស្អាត អនាម័យ ជាពិសេសប្រាក់ចំណូលគ្រួសារនៅទាបនៅឡើយ ដែលត្រូវបង្កើនទាំងសកម្មភាព និងថវិកាអោយទៅដល់ទីជនបទ។ កិច្ចការដូចភ្លៀងរលឹមនេះ នៅតែបន្តខិតខំប្រឹងប្រែងដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរីថែមទៀត តាមរយៈការចង្អុលបង្ហាញរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជា**ឯកឧត្តមអភិបាលខេត្ត** ជាពិសេសក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។